ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃពុធ ១ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩*

# សេចក្តីប្រកាសព័ត៌មានស្តីពីជំនួបសវនការរវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាទេសាភិបាលកម្ពុជាប្រចាំធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងគណៈប្រតិភូក្រុមប្រឹក្សានាយកប្រតិបត្តិ ធនាគារអភិវឌ្ឍន៍អាស៊ី ដឹកនាំដោយលោក ស៊ីវ៉ាជី ក្សត្រាប៉ាធី (Mr. Shivaji Kshatrapati)

នាថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៩ វេលាម៉ោង ៤:០០ រសៀល, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាទេសាភិបាលកម្ពុជាប្រចាំធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានទទួលជួបសវនការការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ ADB ដឹកនាំដោយលោក **ស៊ីវ៉ាជី ក្សត្រាប៉ាធី** (Mr. Shivaji Kshatrapati) នាយកប្រតិបត្តិរបស់ ADB ទទួលបន្ទុកប្រទេសអាហ្គានីស្ថាន, បង់ក្លាដេស, ប៊ូតាន់, ឥណ្ឌា, ឡាវ, តាជីគីស្ថាន, និងតួកមេនីស្ថាន ព្រមទាំងនាយកប្រតិបត្តិ និងនាយកប្រតិបត្តិជំនួស ដែលតំណាងអោយប្រទេសសមាជិកផ្សេងទៀត ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជាពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច, ថវិកា និងបំណុល និងការអភិវឌ្ឍន៍ប្រទេសរបស់កម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជារបស់គណៈប្រតិភូ ADB ហើយបានសម្តែងនូវអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះការគាំទ្រ និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររបស់ ADB ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនប្រតិភូអំពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដែលកំពុងសម្រេចបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ទោះបីត្រូវជួបប្រទះនូវបញ្ហាប្រឈមនិងហានិភ័យពីខាងក្រៅមួយចំនួនក៏ដោយ ដែលប្រការនេះ **គឺជាការសបញ្ជាក់ឱ្យឃើញថា កម្ពុជាកំពុងតែដើរនៅលើផ្លូវត្រូវ** ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ថា សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនក្នុងរង្វង់ ៧% ក្នុងឆ្នាំ ២០១៨ និងតាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចនេះនឹងអាចនៅតែសម្រេចបានប្រមាណ ៧% ក្នុងឆ្នាំ ២០១៩ នេះផងដែរ ។ ចាប់ពីពេលនេះតទៅ, ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នឹងជួយកម្ពុជាឱ្យឈានទៅសម្រេចបានជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះ ADB ដែលបានផ្តល់ដល់កម្ពុជាទាំងហិរញ្ញប្បទានសហប្រតិបត្តិការ, ចំណេះដឹង និងចំណេះធ្វើ ដល់វិស័យអាទិភាព ដូចជា ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ ធារាសាស្ត្រ អគ្គិសនី ទឹកស្អាត អប់រំ និងសុខាភិបាល ។ល។ ហើយដែលបានរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព ។

លោក **ក្សេត្រាប៉ាឌី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងអបអរសាទរចំពោះជោគជ័យដ៏ធំធេងរបស់កម្ពុជាក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដោយរក្សាបាននូវចីរភាពនៃកំណើនក្នុងរង្វង់ ៧% ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងមកនេះ, ការគ្រប់គ្រងអតិផរណាឱ្យនៅទាប, ការគ្រប់គ្រងថវិកាបានរឹងមាំល្អ និងការគ្រប់គ្រងបំណុលប្រកបដោយចីរភាព ព្រមទាំង សម្រេចបាននូវគោលដៅអភិវឌ្ឍសហសវត្សមុនកាលកំណត់ ។ ទន្ទឹមនេះ, លោកបានជម្រាបថា ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០១៩-២០២៣, ADB នឹងបន្តគាំទ្ររាជរដ្ឋាភិបាលកម្ពុជាលើកិច្ចអភិវឌ្ឍស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ជាពិសេស គឺផ្តោតលើការវិនិយោគលើការបង្កើនទិន្នផលកសិកម្ម, ការតភ្ជាប់ទីជនបទទៅកាន់ទីប្រជុំជន, ការផ្គត់ផ្គង់អគ្គិសនីដោយប្រើប្រាស់ថាមពលកកើតឡើងវិញ, ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង, ការអភិវឌ្ឍន៍វិស័យអប់រំកម្រិតទុតិយភូមិ, ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើវិមជ្ឈការសេវាសាធារណៈ ។ ជាមួយគ្នា, ADB គាំទ្រដល់ដំណើរការអភិវឌ្ឍន៍វិស័យធនធានមនុស្សរបស់រាជរដ្ឋាភិបាល, ការអភិវឌ្ឍន៍វិស័យថាមពលដើម្បីកំណើនសេដ្ឋកិច្ចខ្ពស់, បង្កើនចំណេះដឹងផ្នែកអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ការរៀបចំហិរញ្ញវត្ថុសាធារណៈប្រកបដោយបរិយាប័ន្ន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានណែនាំឱ្យការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០១៩-២០២៣ ដោយមានភាគីកម្ពុជាជាម្ចាស់ក្នុងការដឹកនាំរៀបចំឱ្យយុទ្ធសាស្ត្រ ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងរបស់កម្ពុជា ដូចជា (១) វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, (២) គោលដៅអភិវឌ្ឍន៍ប្រកបនិរន្តភាពរបស់កម្ពុជា, (៣) ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម, (៤) កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ, (៥) ការពង្រឹងអភិបាលកិច្ច, និង (៦) សេដ្ឋកិច្ចឌីជីថល ជាដើម ។

ទន្ទឹមនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានស្វាគមន៍ចំពោះសុភវិនិច្ឆ័យរបស់ ADB ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានស្តែងឡើងតាមរយៈការបង្ហាញជំហរច្បាស់លាស់ក្នុងការបន្តគាំទ្រ និងពង្រីកកិច្ចសហប្រតិបត្តិការនៅកម្ពុជាហើយ ADB នៅតែបន្តដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការអភិវឌ្ឍប្រទេសកម្ពុជាក្នុងភាពជាដៃគូល្អ និងស្មើភាពគ្នា ។

ឆ្លៀតក្នុងដំណើរទស្សនកិច្ចនេះ, គណៈប្រតិភូ ADB ក៏បានជួបពិភាក្សាការងារជាមួយតំណាងស្ថាប័នផ្សេងៗរបស់រាជរដ្ឋាភិបាល និងតំណាងវិស័យឯកជន ព្រមទាំង ចុះពិនិត្យផ្ទាល់គម្រោងមួយចំនួនដែលហិរញ្ញប្បទានដោយ ADB ដូចជា គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រតំបន់ខ្ពង់រាប និងការគ្រប់គ្រងវិស័យធនធានទឹក, គម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានជូនពរ លោក **ស៊ីវ៉ាជី ក្សេត្រាប៉ាឌី** និងគណៈប្រតិភូក្រុមប្រឹក្សានាយកប្រតិបត្តិ ADB ឱ្យទទួលបានជោគជ័យក្នុងបេសកកម្មការងាររបស់ខ្លួននៅកម្ពុជា ។